**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ១៦៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តា ស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីក្របខ័ណ្ឌមុខងារ ភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីជៀសវាងការអនុវត្តស្ទួនគ្នា ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយកំណត់មុខងារភារកិច្ចរបស់÷

- សវនកម្មផ្ទៃក្នុងរបស់បណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ
- អធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- អធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អធិការកិច្ចមុខងារសាធារណៈរបស់ក្រសួងមុខងារសាធារណៈ
- អធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមុខងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ចរបស់ក្រសួង ស្ថាប័ន អធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អធិការកិច្ចមុខងារសាធារណៈរបស់ក្រសួងមុខងារសាធារណៈ និងអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ជំពូកទី២

## មុខងារ និងភារកិច្ចរបស់សវនកម្មផ្ទៃក្នុង និងអធិការកិច្ច

### ផ្នែកទី១

### សវនកម្មផ្ទៃក្នុង

**មាត្រា៣.-**

សវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង ស្ថាប័ន សហគ្រាសសាធារណៈ បំពេញមុខងារជាសេនាធិការចំណុះផ្ទាល់រដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័នដោយទទួលបន្ទុកអនុវត្តភារកិច្ចស្របតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា និងអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុង នៅតាមបណ្តាស្ថាប័ន ក្រសួង និងសហគ្រាសសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ផ្នែកទី២

### អធិការកិច្ចរបស់ក្រសួង ស្ថាប័ន

**មាត្រា៤.-**

អគ្គាធិការដ្ឋាន ឬអធិការដ្ឋាននៅតាមក្រសួង ស្ថាប័ន ជាអង្គភាពអធិការកិច្ចស្ថិតក្រោមការដឹកនាំ និងគ្រប់គ្រងរបស់ក្រសួង ស្ថាប័នសាមី មានភារកិច្ចធ្វើអធិការកិច្ចក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នសាមីនីមួយៗ។

**មាត្រា៥.-**

អគ្គាធិការដ្ឋាន ឬអធិការដ្ឋាននៅតាមក្រសួង ស្ថាប័នមានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- ធ្វើអធិការកិច្ចក្នុងសមត្ថកិច្ចតាមវិស័យដែលកំណត់ដោយក្រសួង ស្ថាប័នសាមី ដើម្បីធានាប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- ធ្វើអធិការកិច្ចក្នុងសមត្ថកិច្ចតាមវិស័យដែលកំណត់ដោយក្រសួង ស្ថាប័នសាមី ដោយផ្អែកលើអភិក្រមហានិភ័យ និងករណីសង្ស័យ
- ទទួល និងធ្វើអធិការកិច្ចតាមពាក្យបណ្តឹងតវ៉ា និងបណ្តឹងបរិហាររបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល និងមជ្ឈដ្ឋានពាក់ព័ន្ធក្នុងសមត្ថកិច្ចរបស់ក្រសួង ស្ថាប័នសាមី
- ចាត់វិធានការដោយផ្ទាល់ ឬលើកសំណើចាត់វិធានការទៅថ្នាក់ដឹកនាំក្រសួង ស្ថាប័នក្នុងសមត្ថកិច្ចដែលកំណត់ដោយក្រសួង ស្ថាប័នសាមី
- សហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង ស្ថាប័នសាមី ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ធ្វើរបាយការណ៍លទ្ធផលអធិការកិច្ចជិនាញជូនថ្នាក់ដឹកនាំក្រសួង ស្ថាប័នសាមី
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់ថ្នាក់ដឹកនាំក្រសួង ស្ថាប័នសាមី។

## ផ្នែកទី៣
## អធិការកិច្ចហិរញ្ញវត្ថុ

**មាត្រា៦.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋនៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នីតិបុគ្គលសាធារណៈ និងឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដោយអនុលោមតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចរៀបចំរបាយការណ៍លទ្ធផលអធិការកិច្ចហិរញ្ញវត្ថុប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

**មាត្រា៧.-**

អធិការកិច្ចហិរញ្ញវត្ថុមានបេសកកម្មត្រួតពិនិត្យលើអនុលោមភាព សមិទ្ធកម្ម នៃការគ្រប់គ្រង និងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយផ្អែកលើហានិភ័យ ករណីសង្ស័យ បណ្តឹងតវ៉ា និងបណ្តឹងបរិហារ ដើម្បី÷

- ចូលរួមធានាការរក្សាវិន័យហិរញ្ញវត្ថុសាធារណៈ ព្រមទាំងធានាការគោរព និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋ
- កំណត់អំពើបំពានហិរញ្ញវត្ថុសាធារណៈសំដៅធានាការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋតាមរយៈការចាត់វិធានការឱ្យទទួលខុសត្រូវ
- បង្ការ និង/ឬ ចាត់វិធានការចំពោះការប្រព្រឹត្តកំហុសដោយចេតនា ឬអចេតនា លើការគ្រប់គ្រង និង/ឬការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- ធានាបូរណភាព និងសង្គតិភាពនៃព័ត៌មាន និងទិន្នន័យហិរញ្ញវត្ថុសម្រាប់ការចូលរួមរៀបចំថវិកា និងទូទាត់ថវិកាប្រចាំឆ្នាំ។

## ផ្នែកទី៤
## អធិការកិច្ចមុខងារសាធារណៈ

**មាត្រា៨.-**

ក្រសួងមុខងារសាធារណៈ ជាសេនាធិការបច្ចេកទេសរបស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការអធិការកិច្ចលើការងារមុខងារសាធារណៈ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ មានភារកិច្ចរៀបចំរបាយការណ៍លទ្ធផលអធិការកិច្ចមុខងារសាធារណៈប្រចាំឆ្នាំជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ផ្នែកទី៥
## អធិការកិច្ច របស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

**មាត្រា៩.-**

ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ជាអធិការកិច្ចរាជរដ្ឋាភិបាល មានភារកិច្ចធ្វើអធិការកិច្ចលើគ្រប់វិស័យស្របតាមអនុក្រឹត្យលេខ ០៣ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច និងដោយផ្អែកលើអភិក្រមដូចខាងក្រោម÷

- តាមបណ្ដឹងតវ៉ា និងបណ្ដឹងបរិហារពីនីតិបុគ្គល រូបវន្តបុគ្គល និងគ្រប់មជ្ឈដ្ឋាន
- តាមបណ្ដឹងរបស់ស្ថាប័នរងអធិការកិច្ចលើលទ្ធផលអធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- ផ្អែកលើហានិភ័យ បណ្ដឹងតវ៉ា ឬភាពចាំបាច់ក្នុងការផ្ទៀងផ្ទាត់ព័ត៌មាន ឬរបាយការណ៍ពាក់ព័ន្ធ
- តាមសំណើរបស់ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ
- មានភាពមិនប្រក្រតីលើរបាយការណ៍លទ្ធផលអធិការកិច្ច
- តាមដាននូវរាល់វិធានការដែលអធិការកិច្ចបានដាក់ចេញដល់ស្ថាប័នរងអធិការកិច្ច និង
- តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

**មាត្រា១០.-**

ការចុះធ្វើអធិការកិច្ចរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ត្រូវជូនដំណឹងដល់អធិការកិច្ចរបស់ក្រសួង ស្ថាប័ន ដើម្បីផ្ដល់កិច្ចសហការ លើកលែងតែ÷

- តាមបណ្ដឹងរបស់ស្ថាប័នរងអធិការកិច្ចលើលទ្ធផលអធិការកិច្ចរបស់ក្រសួង ស្ថាប័ន
- តាមបញ្ជារបស់ប្រមុខរាជរដ្ឋាភិបាល។

## ផ្នែកទី៦
## ភាគព្វកិច្ចរបស់ក្រសួង ស្ថាប័ន

**មាត្រា១១.-**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នត្រូវបែងចែកភារកិច្ច របៀបរបបបំពេញការងាររវាងសវនកម្មផ្ទៃក្នុង អគ្គាធិការដ្ឋាន ឬអធិការដ្ឋាន ព្រមទាំងអង្គភាពផ្សេងទៀតដែលមានសមត្ថកិច្ចត្រួតពិនិត្យ ឱ្យបានសមស្របជៀសវាងការត្រួតពិនិត្យស្ទួនគ្នា និងស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

**មាត្រា១២.-**

បន្ទាប់ពីឯកភាពលើរបាយការណ៍ចុងក្រោយនៃលទ្ធផលអធិការកិច្ចតាមករណី រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន មានភារកិច្ចផ្ញើរបាយការណ៍នេះជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ។

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័ន មានភារកិច្ចរៀបចំរបាយការណ៍លទ្ធផលអធិការកិច្ចប្រចាំឆ្នាំតាមសមត្ថកិច្ចរៀងៗខ្លួនជូនប្រមុខរាជរដ្ឋាភិបាល និងចម្លងជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច។

## ជំពូកទី៣

## អវសានប្បញ្ញត្តិ

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ៦ រោច ខែ អស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ តុលា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ